# តម្រូវការចាំបាច់ទាំងឡាយរបស់នាយកដ្ឋានសុខភាពសាធារណៈចំពោះការប្រើប្រាស់យានយន្តសម្រាប់រស់នៅពេលដើរកម្សាន្ត និងផ្ទះចល័ត ជាបណ្ដោះអាសន្ននៅលើដីដែលបានទទួលរងការប៉ះពាល់ដោយករណីភ្លើងឆេះ

ថ្ងៃទី 27 ខែកុម្ភៈ ឆ្នាំ 2025

ផ្នែកសុខភាពបរិស្ថាន (ENVIRONMENTAL HEALTH)

ខណៈពេលដែលអ្នកសាងសង់ផ្ទះរបស់អ្នកសាជាថ្មី អ្នកអាចនឹងប្រើប្រាស់យានយន្តសម្រាប់រស់នៅពេលដើរកម្សាន្ត (Recreational Vehicle/RV) ឬក៏ផ្ទះចល័ត (Mobile Home) ជាទីកន្លែងសម្រាប់ស្នាក់នៅជាបណ្ដោះអាសន្ន។ មុនពេលប្រើប្រាស់ទីកន្លែងសម្រាប់ស្នាក់នៅជាបណ្ដោះអាសន្ននោះ សូមសាកសួរទៅកាន់នាយកដ្ឋានផ្នែកការរៀបចំផែនការសម្រាប់ទីក្រុង (city planning departments) នៅក្នុងតំបន់របស់អ្នក ដើម្បីដឹងអំពីតម្រូវការចាំបាច់ និងការអនុម័តឱ្យប្រើប្រាស់ទាំងឡាយ។ ឯកសារណែនាំនេះផ្ដល់ព័ត៌មានអំពីតម្រូវការចាំបាច់ទាំងឡាយរបស់នាយកដ្ឋានសុខភាពសាធារណៈ (Department of Public Health/DPH) ចំពោះទីកន្លែងសម្រាប់ស្នាក់នៅជាបណ្ដោះអាសន្ន។

## ការចាក់ចោលទឹកសម្អុយ

**កម្មវិធីផ្នែកការចាត់ចែងទឹកសម្អុយនៅតាមផ្ទះ (Onsite Wastewater Treatment Program)៖** (626) 430-5380

ដើម្បីទទួលបានការអនុម័តពី DPH សម្រាប់ការចាក់ចោលទឹកសម្អុយពី RV ឬផ្ទះចល័តនោះ សូមដាក់បញ្ជូនឯកសារទាំងឡាយខាងក្រោមនេះសម្រាប់ការពិនិត្យមើលឡើងវិញ៖

| | | |
|---|---|---|
| **យានយន្តសម្រាប់រស់នៅក្នុងពេលដើរកម្សាន្ត (RVs)** រួមមានរថយន្តដែលជាផ្ទះ (motorhomes) ផ្ទះសណ្ដោងខ្នាតមធ្យម (travel trailers) ផ្ទះសណ្ដោងខ្នាតតូច (camping trailer) ផ្ទះសណ្ដោងខ្នាតធំ (fifth wheel trailers) ឬក៏រថយន្តដឹកទំនិញតូចៗដែលមានកន្លែងស្នាក់នៅ (truck campers) ប៉ុន្តែមិនមែនមានត្រឹមតែប្រភេទទាំងនេះទេ។ | **ជម្រើសទី 1** | ដើម្បីប្រើប្រាស់ប្រព័ន្ធចាត់ចែងទឹកសម្អុយដែលមានស្រាប់នៅនឹងទីតាំងដី សូមដាក់បញ្ជូនបែបបទខាងក្រោមនេះ៖<br>**"System Evaluation Form for Existing Onsite Wastewater Treatment System (OWTS) (បែបបទផ្នែកការវាយតម្លៃទៅលើប្រព័ន្ធដំណើរការចំពោះប្រព័ន្ធចាត់ចែងទឹកសម្អុយនៅតាមផ្ទះដែលមានស្រាប់)"** ហើយដែលបានបំពេញដោយអ្នកម៉ៅការមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ (Qualified Contractor/QC) ផ្នែកប្រព័ន្ធចាត់ចែងទឹកសម្អុយ។ QC គឺជាបុគ្គលម្នាក់ដែលមានអាជ្ញាប័ណ្ណសម្រាប់អ្នកម៉ៅការនៅក្នុងរដ្ឋ California (California Contractors' License) ត្រឹមត្រូវ ដូចជា៖ Class A ឬ C 42 ឬក៏ C 36។<br>**បែបបទនេះគឺអាចរកបាននៅលើគេហទំព័រ៖**<br>http://publichealth.lacounty.gov/eh/business/septic-systems.htm។ |
| | **ជម្រើសទី 2** | ដើម្បីឱ្យមានការបូមយកពីអាងស្តុកទឹកសម្អុយរបស់ RV អ្នកនៅនឹងទីតាំងតែម្តងនោះ សូមផ្តល់ច្បាប់ចម្លងនៃកិច្ចសន្យានាពេលឥឡូវនេះជាមួយនឹងក្រុមហ៊ុនបូមទឹកសម្អុយដែលមានអាជ្ញាប័ណ្ណសម្រាប់ដំណើរការនៅក្នុងខោនធី Los Angeles។ |

សូមមើលទំព័របន្ទាប់

| | |
|---|---|
| **ផ្ទះចល័ត (Mobile Homes)** | ដើម្បីប្រើប្រាស់ប្រព័ន្ធចាត់ចែងទឹកសម្អុយដែលមានស្រាប់នៅនឹងទីតាំងដី សូមដាក់បញ្ជូនបែបបទខាងក្រោមនេះ៖<br><br>**"System Evaluation Form for Existing Onsite Wastewater Treatment System (OWTS) (បែបបទផ្នែកការវាយតម្លៃទៅលើប្រព័ន្ធដំណើរការចំពោះប្រព័ន្ធចាត់ចែងទឹកសម្អុយនៅតាមផ្ទះដែលមានស្រាប់)"** ហើយដែលបានបំពេញដោយអ្នកម៉ៅការមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ (Qualified Contractor/QC) ផ្នែកប្រព័ន្ធចាត់ចែងទឹកសម្អុយ។ QC គឺជាបុគ្គលម្នាក់ដែលមានអាជ្ញាប័ណ្ណសម្រាប់អ្នកម៉ៅការនៅក្នុងរដ្ឋ California (California Contractors' License) ត្រឹមត្រូវ ដូចជា៖ Class A ឬ C 42 ឬក៏ C 36។<br><br>**បែបបទនេះគឺអាចរកបាននៅលើគេហទំព័រ៖** http://publichealth.lacounty.gov/eh/business/septic-systems.htm។ |

***មានតែប្រព័ន្ធចាត់ចែងទឹកសម្អុយដែលមានការអនុម័តឱ្យប្រើប្រាស់ពី DPH ឬនាយកដ្ឋានអគារ និងផ្នែកសុវត្ថិភាព (Building and Safety Department/B&S) ក្នុងតំបន់ដែលទទួលបានពីពេលកន្លងមកប៉ុណ្ណោះ ដែលអ្នកមានសិទ្ធិក្នុងការប្រើប្រាស់ជាមួយនឹងយានយន្តសម្រាប់ស្នាក់នៅជាបណ្ដោះអាសន្ននេះ។ ដើម្បីស្នើសុំច្បាប់ចម្លងនៃការអនុម័តឱ្យប្រើប្រាស់ប្រព័ន្ធចាត់ចែងទឹកសម្អុយពីពេលកន្លងមក សូមទាក់ទងទៅកាន់ Onsite Wastewater Treatment Program ឬនាយកដ្ឋានអគារ និងផ្នែកសុវត្ថិភាព (Building and Safety Department) នៅក្នុងតំបន់របស់អ្នក។**

## ទឹកដែលមានសុវត្ថិភាពអាចញ៉ាំបាន

**កម្មវិធីផ្នែកទឹកអាចញ៉ាំបាន (Drinking Water Program)៖** (626) 430-5420

តម្រូវការចាំបាច់ចំពោះទឹកដែលមានសុវត្ថិភាពអាចញ៉ាំបាន៖

- ប្រសិនបើក្រុមហ៊ុនផ្ដល់សេវាកម្មសាធារណៈផ្នែកទឹក (ឧ. LA DWP ឬ Las Flores Water Company ឬ Kinneloa Irrigation District ឬ LA County Waterworks District 29 ជាដើម) បម្រើការជូនដល់អ្នកនោះ នាយកដ្ឋានសុខភាពសាធារណៈនឹងទាក់ទងទៅកាន់ក្រុមហ៊ុនផ្ដល់សេវាកម្មសាធារណៈផ្នែកទឹករបស់អ្នក ដើម្បីទទួលបានព័ត៌មានថាមានទឹកសម្រាប់ប្រើប្រាស់ឬទេ។ ប្រសិនបើអ្នកទទួលបានទឹកសម្រាប់ញ៉ាំពីអណ្ដូងដែលស្ថិតនៅក្នុងទីតាំងដីរបស់អ្នក៖
  - សូមដាក់បញ្ជូន **"Well Reuse Application (បែបបទសម្រាប់ការប្រើប្រាស់អណ្ដូងទឹកសាជាថ្មី)"** ដែលបានបំពេញត្រឹមត្រូវ ទៅកាន់ Drinking Water Program សម្រាប់ការពិនិត្យមើលឡើងវិញ និងការអនុម័តឱ្យប្រើប្រាស់។ ឯកសារ "Well Reuse Application" នេះគឺអាចរកបាននៅលើគេហទំព័រ៖ http://publichealth.lacounty.gov/eh/safety/small-water-systems-wells.htm។
  - បន្ទាប់ពីការអនុម័តទៅលើឯកសារ "Well Reuse Application" នេះរួច Drinking Water Program នឹងចេញ **Water Availability Letter (លិខិតបញ្ជាក់អំពីការមានទឹកសម្រាប់ប្រើប្រាស់)** សម្រាប់ការដាក់បញ្ជូនជាមួយនឹងបែបបទស្នើសុំរបស់អ្នកទៅកាន់នាយកដ្ឋានផ្នែកការរៀបចំផែនការនៅតាមតំបន់ (Department of Regional Planning/DRP។

ប្រសិនបើអ្នកមានស្ថានភាពមួយដែលមានលក្ខណៈពិសេស ឬត្រូវការព័ត៌មានបន្ថែមទៀតជាចាំបាច់នោះ សូមទាក់ទងទៅកាន់ **Onsite Wastewater Treatment Program** តាមរយៈលេខ **(626) 430-5380**។